ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

តាងនាមប្រជារាស្ត្រខ្មែរ

សាលាឧទ្ធរណ៍ភ្នំពេញ

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៨៩៤
ចុះថ្ងៃទី ០៥_១១_២០១០
សាលដីកាព្រហ្មទណ្ឌ
លេខ : ១៧ "ក្រ.VI សទ"
ចុះថ្ងៃទី ០៦_០២_២០១២

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍ នាថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០១២ ដោយមានសមាសភាពដូចខាងក្រោម:

ក្រុមប្រឹក្សាជំនុំជម្រះ

- ឯកឧត្តម. [redacted] ជាប្រធាន
- ឯកឧត្តម [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ចៅក្រមប្រឹក្សា

តំណាងមហាអយ្យការ

លោ[redacted]

ក្រឡាបញ្ជីសវនាការ

លោក[redacted]

**ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៨៩៤ ចុះថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ២០១០ ដែលមាន:**

១- ជនជាប់ចោទឈ្មោះ[redacted] ភេទប្រុស អាយុ ១៩ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោ[redacted] ម្តាយឈ្មោ[redacted] (ស) កំរិតវប្បធម៌ថ្នាក់ទី ៧ ចាប់ខ្លួនថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០០៨ ឃុំខ្លួនតាមដីការបង្គាប់ឱ្យឃុំ ខ្លួនលេខ ៧១០ ត.ព្រ ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០០៨។

២- ជនជាប់ចោទឈ្មោ[redacted]ភេទប្រុស អាយុ ២១ឆ្នាំ ជាតិខ្មែរ ទីលំនៅមុនពេលចាប់ខ្លួន ផ្ទះលេខ ៣៦១D ផ្លូវលេខ២៦៨ ភូមិ៥ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោ[redacted] ម្តាយឈ្មោះ [redacted]) នៅលីវ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០០៩ ឃុំខ្លួនតាមដីការបង្គាប់ឱ្យឃុំខ្លួនលេខ ៣៣១០ ត.ព្រ ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០៩។



Scanned by CamScanner

មានលេ[redacted]ធាវីការពារជនជាប់ចោទឈ្មោ[redacted]

**ជាប់ចោទពីបទ: ប្លន់ (ម៉ូតូ)** ប្រព្រឹត្តនៅចំណុចព្រះអង្គដងកើ ផ្លូវព្រះស៊ីសុវត្ថិ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

- ជនរងគ្រោះឈ្មោះ[redacted]ភេទប្រុស ជាតិខ្មែរ ទីលំនៅផ្ទះលេខ ២៣៥ ផ្លូវមុនីវង្ស សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ។

## ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ

កាលពីថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០០៨ នៅចំណុចព្រះអង្គដងកើ ផ្លូវព្រះស៊ីសុវត្ថិ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ មានករណី ប្លន់ (វាយយកម៉ូតូ) មួយកើតឡើង ដែលបង្កឡើងដោយជនល្មើស ឈ្មោ[redacted] និងឈ្មោ[redacted]មទាំងបក្សពួក ៦នាក់ទៀត បានធ្វើសកម្មភាពវាយយក ម៉ូតូរបស់ជនរងគ្រោះឈ្មោះ[redacted]បណ្តាលឱ្យជនរងគ្រោះត្រូវរបួស ភ្លាមនោះជនរងគ្រោះក៏បានផ្តួលម៉ូតូចោល ហើយរត់គេចខ្លួន ហើយជនល្មើស ឈ្មោះ[redacted]ប៉ុរុងលើកម៉ូតូជនរងគ្រោះជិះចេញ ក៏ត្រូវសមត្ថកិច្ចមកដល់ឃាត់ខ្លួនបានឈ្មោ[redacted] រីឯបក្សពួករបស់ជនល្មើស ផ្សេងទៀតបានរត់គេចខ្លួនអស់តែម្តង។

**បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៩៣ កប៣ "ឆ" ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០១០ របស់សាលាដំបូង រាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:**

១- ផ្តន្ទាទោស:

- ឈ្មោះ[redacted]ភេទប្រុស អាយុ ១៩ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

- ឈ្មោះ [redacted]ភេទប្រុស អាយុ ២១ឆ្នាំ ជាតិខ្មែរ ទីលំនៅមុនពេលចាប់ខ្លួនផ្ទះលេខ ៣៦១០ ផ្លូវលេខ៦៨ ភូមិ៥ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ ០៦ឆ្នាំ (ប្រាំមួយឆ្នាំ) គិតពីថ្ងៃឃុំខ្លួន ពីបទ ប្លន់ (ម៉ូតូ) ប្រព្រឹត្តនៅចំណុចព្រះអង្គដងកើ ផ្លូវព្រះស៊ីសុវត្ថិ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០០៨ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

២- សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី ០៤ ខែឧសភា ឆ្នាំ២០១០ និងប្រកាសជាសាធារណៈនៅថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០១០ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted]ឈ្មោះ [redacted]និងមេធាវីការពារជនជាប់ចោទលោក[redacted]លោកស្រី[redacted]ទាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted]សិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។





Scanned by CamScanner

78

- បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០១០ របស់[redacted]ឈ្មោះ[redacted]ឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៩៣ កបព "ឆ" ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍។

- បានឃើញរបាយការណ៍រឿងព្រហ្មទណ្ឌរបស់ចៅក្រមរបាយការណ៍ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍។

## នាពេលសវនាការ

- ជនជាប់ចោទឈ្មោះ[redacted] (វត្តមាន)
- ជនជាប់ចោទឈ្មោះ[redacted] (វត្តមាន)
- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] (អវត្តមាន)
- លោក[redacted]មេធាវីការពារជនជាប់ចោទឈ្មោះ[redacted] (វត្តមាន)

ជនជាប់ចោទឈ្មោះ[redacted]ឆ្លើយថា: ក្នុងរឿងនេះខ្លួនគ្រាន់តែវាយគ្នាទេ មិនបានយកម៉ូតូគេទេ ហើយមូលហេតុដែលវាយគ្នាមកពីគេជេរខ្លួន ខ្លួនបានចុះវាយគេតែម្តង។ ខ្លួនចូលផឹកស៊ីទៅទួលគោកមានគ្នា ៦នាក់ ពេលផឹកចប់ទៅម៉ោង ៩ និង៣០នាទី យប់ ខ្លួនក៏ជិះដើរលេងនៅទល់មុខសួន នៅពេលខ្លួនជិះចុះឡើងមានគេជេរខ្លួន ទើបខ្លួនចុះវាយតែម្តងទៅ តែខ្លួនវាយតែម្នាក់ឯងទេ ពេលជិះម៉ូតូខ្លួនជិះជាមួយ[redacted]ទត្រូវគេចាប់នៅកន្លែងកើតហេតុ។

ជនជាប់ចោទ[redacted]ឆ្លើយថា: ខ្លួនមិនបាននៅក្នុងហេតុការណ៍នេះទេ ខ្លួននៅផ្ទះ ខ្លួនមិនដែលស្គាល់ឈ្មោះ[redacted] នៅពេលផឹកស៊ីនៅទួលគោកខ្លួនបានធ្វើដំណើរមកផ្ទះវិញ ឃើញមានភាពអ៊ូអរតាមផ្លូវខ្លួនក៏មិនបានឈប់មើលទេ នៅពេលផឹកស៊ីខ្លួនចូលផឹកនៅម៉ោង ៩យប់ ពេលផឹកចប់ខ្លួនមកមាត់ទន្លេមានគ្នាបីនាក់ដដែលគេចាប់ខ្លួនតាមដីកាចុងឆ្នាំ២០០៩។

**តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ធ្វើសេចក្តីសន្និដ្ឋានថា:** ដោយបទល្មើសនេះជាបទល្មើសជាក់ស្តែងការសម្រេចរបស់តុលាការមានលក្ខណៈត្រឹមត្រូវ ដូច្នេះ សុំតម្កល់សេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោមដដែល។

លោក[redacted]ធាវីការពារជនជាប់ចោទ ធ្វើសេចក្តីសន្និដ្ឋានថា: នៅចំពោះមុខអង្គសវនាការ កូនក្តីខ្លួនពុំបានឆ្លើយថា ចូលរួមធ្វើសកម្មភាពជាក់ស្តែងទេ កូនក្តីខ្លួនឈ្មោះ[redacted]ឆ្លើយថា ទៅហូបចុកមានគ្នាតែ ៣នាក់ទេ រីឯឈ្មោះ[redacted]គ្នា ៦ ទៅ ៧នាក់ ហើយហូបនៅតុផ្សេងគ្នា ពេលហូបហើយកូនក្តីខ្លួនចេញក្រោយគេហើយបានជិះដើរលេងតាមដងផ្លូវមាត់ទន្លេ ក៏ឃើញហេតុការណ៍កើតឡើង កូនក្តីខ្លួនបានចុះមើល ចំណែក[redacted]ចុះវាយគេនៅពេលគេជេរកូនក្តីខ្លួន។ សូមតុលាការពិនិត្យមើលចរិកលក្ខណៈរបស់កូនក្តីខ្លួន ព្រោះនៅផ្ទះកូនក្តីខ្លួនបានបង្រៀនភាសាអង់គ្លេស និងបង្រៀនដល់ជនជាប់ចោទផ្សេងទៀតឱ្យចេះធ្វើតុទូ។ សំណូមពរ សុំឱ្យកូនក្តីខ្លួនរួចផុតពីទោសផង ចំពោះឈ្មោះ[redacted]ឱ្យតុលាការបន្ធូរបន្ថយទោសមកកម្រិតអប្បរមា។

- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

- ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិនិត្យពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

**សភាព្រហ្មទណ្ឌ យល់ឃើញថា**

១- បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០១០ របស់ឈ្មោ[redacted] និងឈ្មោ[redacted] ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៩៣ កបព "ឆ" ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច បានធ្វើឡើងត្រឹមត្រូវក្នុងកំណត់ច្បាប់ សភាព្រហ្មទណ្ឌទទួលជំនុំជម្រះបាន យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២- តាមលទ្ធផលនៃកិច្ចពិភាក្សាដេញដោល ឃើញថា កាលពីថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០០៨ ជនជាប់ចោទ ពេ[redacted]: និងឈ្មោ[redacted]តជាបានរួមគំនិតគ្នាធ្វើសកម្មភាពវាយជនរងគ្រោះបំណងយកម៉ូតូរបស់ជនរងគ្រោះនៅចំណុចព្រះអង្គដងកើ ហើយនៅពេលធ្វើសកម្មភាពនោះក៏ត្រូវសមត្ថកិច្ចធ្វើអន្តរាគមន៍ចាប់ខ្លួនយ៉ាងជាក់ស្តែងប្រាកដមែន ដែលជាទម្រង់មួយនៃអំពើមានធាតុផ្សំ និងភស្តុតាងដាក់បន្ទុកលើជនជាប់ចោទ ពីបទ លួចដោយប្រើហិង្សា ដូចមានក្នុងផ្នែកសំអាងហេតុនៃសាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញបញ្ជាក់ស្រាប់ ហើយដែលសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុទាំងនេះ។ ហេតុដូច្នេះ សភាព្រហ្មទណ្ឌមិនចាំបាច់លើកយកសំអាងហេតុដដែលនេះមកបញ្ជាក់ជាថ្មីទៀតទេ។

៣- តាមសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ប្តឹងសុំសភាព្រហ្មទណ្ឌតម្កល់សាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល តែសុំគ្រាន់កែប្រែបទចោទប្រកាន់ ពីមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ទៅជាបទ លួច តាមមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ វិញដែលចំណុចនេះគប្បីសភាព្រហ្មទណ្ឌពិចារណា។

៤- សាលក្រមព្រហ្មទណ្ឌលេខ ៩៣ កបព "ឆ" ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលសម្រេចមកនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ ដែលគប្បីសភាព្រហ្មទណ្ឌតម្កល់ទុកជាបានការ តែដើម្បីផលប្រយោជន៍ផ្លូវច្បាប់ដូចមានចែងក្នុងមាត្រា ១០ នៃក្រមព្រហ្មទណ្ឌ គួរសភាព្រហ្មទណ្ឌសម្រេចកែប្រែបទចោទប្រកាន់ និងទោសឡើងវិញឱ្យបានត្រឹមត្រូវតាមច្បាប់។

**<u>ហេតុដូច្នេះ</u>**

**<u>វិនិច្ឆ័យសេចក្តី</u>**

១- ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០១០ របស់ឈ[redacted]និងឈ្មោះ [redacted]កជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។





Scanned by CamScanner

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៥៣ កបព "ឆ" ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល លើកលែងតែចំណុចទី ១ នៃសាលក្រមនេះត្រូវកែប្រែបទចោទប្រកាន់ ពីបទ ប្លន់តាមមាត្រា ០៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ទៅជាបទ ប៉ុនប៉ងលួចដោយហិង្សា តាមមាត្រា ៣៥៣ មាត្រា ៣៥៧ និងមាត្រា ៣៦១ នៃក្រមព្រហ្មទណ្ឌ វិញ និងកែប្រែទោសដាក់ពន្ធនាគារពីរយៈពេល ០៦ឆ្នាំ ( ប្រាំមួយឆ្នាំ) មកត្រឹម ០៣ឆ្នាំ ( បីឆ្នាំ) វិញ យោងតាមមាត្រា ១០ នៃក្រមព្រហ្មទណ្ឌ ។ ចំណុចផ្សេងពីនេះនៃសាលក្រមត្រូវរក្សាទុកជាបានការដដែល ។

៣- បន្តឃុំខ្លួនជនជាប់ចោទ[redacted]ឹងឈ្មោះ[redacted]តាមនីតិវិធីច្បាប់ ។

៤- សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ។

បើកសិទ្ធិប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

**ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

ហត្ថលេ[redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted]

---

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ ២០១២

**ក្រឡាបញ្ជី**

[redacted]





Scanned by CamScanner